# ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

************

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៩

ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០១

សាលដីកា

លេខ : ១១៥

ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០១

## នាមអង្គព្រះមហាក្សត្រ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម **ខិត ឆុន្នី** ជាប្រធាន

២- លោក ជីវ កេង ជាចៅក្រម

៣- លោក ឈឹម ស៊ីផល ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក សោម សិរីវឌ្ឍ ជាចៅក្រម របាយការណ៍

ក្រឡាបញ្ជី

លោក អ៊ូ សុផុន

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា លេខ ៦២ " ឃ " ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០ នៃ សំណុំរឿងរដ្ឋប្បវេណី លេខ ៤៨ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

- រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ អាន ចំរើន ភេទស្រី អាយុ ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅផ្ទះលេខ ១២Eo ផ្លូវលេខ ១៣០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវី លោក សៅ វិតា

- និងចុងបណ្តឹងសាទុក្ខឈ្មោះ ឈូ ហុង ភេទប្រុស អាយុ៦៧ឆ្នាំ ជាតិខ្មែរ មុខរបរ ជវា ទីលំនៅផ្ទះលេខ ១២Eo ផ្លូវលេខ ១៣០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវី លោក ជាត់ ពៅស៊ាង

- អំពីវិវាទ : ប្តឹងទាមទារផ្ទះលេខ១២Eo ផ្លូវលេខ ១៣០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤១៦ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០០ របស់ អ្នកស្រី អាន ចំរើន ប្តឹងមិនសុខចិត្ត ពីសាលដីកា រដ្ឋប្បវេណី លេខ ៦២ " ឃ " ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ២៩ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់

តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៨-៤-៩៩ របស់លោក ឈូ ហុង ប្តឹងទាមទារផ្ទះលេខ ១២E០ ផ្លូវលេខ ១៣០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ពីឈ្មោះ អាន ចំរើន ដោយសំអាងហេតុថា ខ្លួន និង ឈ្មោះ អាន ចំរើន បានទាក់ទងលួចលាក់ ក្នុងនាមស្រីញី ហើយមករស់នៅលើផ្ទះ លេខ ១២E០ ផ្លូវលេខ១៣០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ លុះដល់ឆ្នាំ ១៩៩៨ នាង អាន ចំរើន មានគំនិតចង់យកដីនៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ និង ផ្ទះរបស់ខ្លួន ព្រមទាំងបានគំរាមរកសម្លាប់ខ្លួន និង បណ្តេញខ្លួនចេញពីផ្ទះទៀត ។ ខ្លួនសំណូមពរសុំឱ្យនាង អាន ចំរើន ប្រគល់ផ្ទះលេខ ១២E០ ផ្លូវលេខ ១៣០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឱ្យខ្លួនវិញ ។

បានឃើញ សាលក្រមលេខ ៧៣ " ក " ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខដើមចោទឈ្មោះ ឈូ ហុង ដែលមានតំណាងឈ្មោះ ប៉ាល់ ចន្ទតារា កំបាំងមុខចុងចម្លើយឈ្មោះ អាន ចំរើន ដែលមានឈ្មោះ លូង សុខា ជាមេធាវី និង ជាតំណាង ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង របស់ដើមចោទឈ្មោះ ឈូ ហុង ចុះថ្ងៃទី ០៨-០៤-៩៩ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់លិខិតប្រគល់សិទ្ធិរបស់ឈ្មោះ ឈូ ហុង ចុះថ្ងៃទី ០៩-០៤-៩៩ ដែលបានប្រគល់សិទ្ធិឱ្យទៅឈ្មោះ ប៉ាល់ ចន្ទតារា ធ្វើជាតំណាង ទុកជាត្រឹមត្រូវ តាមទំរង់ និង គតិច្បាប់ ។

៣- ទទួលស្គាល់ ពាក្យពឹងពាក់មេធាវីរបស់ឈ្មោះ អាន ចំរើន ចុះថ្ងៃទី ០៧-០៥-៩៩ ដែលបានពឹងពាក់មេធាវី ឈ្មោះ លូង សុខា ឱ្យធ្វើជា មេធាវី និង ជាតំណាងពេញសិទ្ធិ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៤- បង្គាប់ឱ្យចុងចម្លើយឈ្មោះ អាន ចំរើន ភេទស្រី អាយុ ៣៩ឆ្នាំ ដែលមានមេធាវី និង ជាតំណាងឈ្មោះ លូង សុខា ប្រគល់ផ្ទះលេខ ១២E០ ផ្លូវលេខ ១៣០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឱ្យទៅដើមចោទឈ្មោះ ឈូ ហុង ភេទប្រុស អាយុ៦៧ ដែលមានតំណាង ឈ្មោះ ប៉ាល់ ចន្ទតារា ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៥- បង្គាប់ឱ្យចុងចម្លើយដែលមានមេធាវី និង ជាតំណាងឈ្មោះ លូង សុខា ភេទប្រុស អាយុ ៣១ឆ្នាំ បង់ប្រាក់ប្រដាប់ក្តី ចំនួន៧០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល ប្រាក់នេះ ត្រូវបានយកពីដើមចោទ បានបង់រួចហើយ ។ កាលបើប្តឹងសបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយឈ្មោះ អាន ចំរើន ភេទស្រី អាយុ ៣៩ឆ្នាំ ដែលមានមេធាវី និង ជាតំណាងឈ្មោះ លូង សុខា សងប្រាក់នេះទៅដើមចោទវិញ និង បង់ពន្ធសមាមាត្រ ចំនួន ១% លើតំលៃជាក់ស្តែង នៃ ផ្ទះ លេខ ១២E០ ផ្លូវលេខ ១៣០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

៦- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទឈ្មោះ ឈូ ហុង ដែលមាន

តំណាងឈ្មោះ ប៉ាល់ ចន្ទតារា កំប៉ាំងមុខចុងចម្លើយឈ្មោះ អាន ចំរើន ដែលមានឈ្មោះ ល្មង សុខា ជាមេធាវី និង ជាតំណាង សំរេចបើកផ្លូវឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ គិតពីថ្ងៃ ផុតបណ្តឹងទាស់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ លេខ ៥៩ " ក " ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩ របស់អ្នកស្រី អាន ចំរើន ប្តឹងមិនសុខចិត្ត នឹង សាលក្រមលេខ ៧៣ " ក " ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសាលក្រមទាំងមូល ។

បានឃើញ សាលក្រមលេខ ៩៥ " ក " ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់របស់ចុងចម្លើយឈ្មោះ អាន ចំរើន ចុះថ្ងៃទី ២៥-០៨-៩៩ ទុកជាត្រឹមត្រូវតាមទំរង់ តែលើកចោល ដោយផ្ទុយគតិច្បាប់ ។

២- តំកល់សាលក្រមរដ្ឋប្បវេណីលេខ ៧៣ " ក " ចុះថ្ងៃទី ២៦-០៧-៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល ។

៣- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី សំរេចបើកផ្លូវឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ គិតពីថ្ងៃ ប្រកាសសាលក្រមនេះតទៅ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ លេខ ៩១ " ក " ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់អ្នកស្រី អាន ចំរើន ប្តឹងមិនសុខចិត្ត នឹង សាលក្រមលេខ ៩៥ " ក " ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណី លេខ ៤១ " ឃ " ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០០ របស់ សាលាឧទ្ធរណ៍ សំរេចចំពោះមុខមេធាវីដើមចោទ កំប៉ាំងមុខចុងចម្លើយ និង ជាដើមបណ្តឹងឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តី សំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ អាន ចំរើន ចុះថ្ងៃទី ១៧-១១-១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៩៥ " ក " ចុះថ្ងៃទី ២២-០៩-១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣- កាត់យកប្រាក់ប្រដាប់ក្តី នៅជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួច គឺ : ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ ចំនួន ៥០០០រៀល សរុប ១៣.០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីដើមចោទ កំប៉ាំងមុខចុងចម្លើយ និង ជាដើមបណ្តឹងឧទ្ធរណ៍ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងទាស់លេខ ៦៣ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០០ របស់អ្នកស្រី អាន ចំរើន ( ពាក្យបណ្តឹងចុះថ្ងៃទី ០៦-៧-២០០០ ) ប្តឹងមិនសុខចិត្ត នឹងសាលដីកា រដ្ឋប្បវេណីលេខ ៤១

ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៦២ " យ " ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខមេធាវីដើមចោទ កំបាំងមុខចុងចម្លើយជាលើកទី២ ចាត់ទុកជាចំពោះមុខ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់ របស់ឈ្មោះ អាន ចំរើន ចុះថ្ងៃទី ០៦-៧-២០០០ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២- តម្កល់សាលដីកាកំបាំងមុខលេខ ៤១ " យ " ចុះថ្ងៃទី ០៨-៦-២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីដើមចោទ កំបាំងមុខចុងចម្លើយជាលើកទី២ ចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ៤១៦ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០០ របស់អ្នកស្រី អាន ចំរើន ប្តឹងមិនសុខចិត្ត នឹងសាលដីកា រដ្ឋប្បវេណី លេខ ៦២ " យ " ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើគ្រប់ចំណុច នៃ សេចក្តីសំរេចទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ២១-០២-២០០១ របស់អ្នកស្រី អាន ចំរើន

បានឃើញ សារណាតប ចុះថ្ងៃទី ១៩-០៣-២០០១ របស់លោកជាត់ ពៅស៊ាង ជាមេធាវីការពារក្តីរបស់លោក ឈូ ហុង .

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា :

សាលដីកា រដ្ឋប្បវេណីលេខ ៦២ " យ " ចុះថ្ងៃទី ០៧-៨-២០០០ របស់សាលាឧទ្ធរណ៍សំរេចមកនេះ មានលក្ខណៈត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេច ។

ក្រឡាបញ្ជីអានសារណាការពាររបស់អ្នកស្រី អាន ចំរើន

បានស្តាប់ចម្លើយរបស់ឈ្មោះ អាន ចំរើន ឆ្លើយថា : ខ្លួនពុំមានអ្វីបញ្ជាក់បន្ថែមលើសារណាទៀតទេ ។ ហើយការដែល ខ្លួនប្តឹងសាទុក្ខនេះ ដោយសាលាឧទ្ធរណ៍កាត់ក្តីកំបាំងមុខខ្លួន ដោយខ្លួនសុំរកមេធាវីសិន ។

ក្រឡាបញ្ជីអានសារណាតបរបស់លោក ឈូ ហុង

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក សៅ វីតា ជាមេធាវីការពារឱ្យចុងចម្លើយ បញ្ជាក់ថាៈ

១- ការលើកឡើងក្នុងសារណាថា អាន ចំរើន ជាស្រីលួចលាក់នោះមិនសមទេ ព្រោះពេលរៀបការ គាត់បានយកប្រពន្ធដើមពីស្រុកបារាំងមកទៀតផង ហើយដេកនៅជាមួយគ្នាទៀត ។ ហើយផ្ទះនេះ អាន ចំរើន បានយកធ្វើជាហាងលក់គុយទាវ ទៀតផង ។

២- តុលាការក្រុងភ្នំពេញ បានចាប់អាន ចំរើន ថា បានក្លែងលិខិតលក់ដីធ្លី ក្នុងរឿងនេះ លោក

ឈូ ហុង បានផ្តិតមេដៃលើក្រដាសសចំនួនប្រាំសន្លឹកទុកឱ្យឈ្មោះ អាន ចំរើន ជាប្រពន្ធមុនគាត់ទៅស្រុកបារាំង សំរាប់ឱ្យ អាន ចំរើន ធ្វើការចាត់ចែងលើអចលនវត្ថុ ។ ហើយការដែលកូនក្តីខ្ញុំចេះតែពន្យាពេលសវនាការនោះ គឺចង់ឱ្យឈ្មោះ ឈូ ហុង ចេញមុខ ព្រោះនេះ ជារឿងអាថ៌កំបាំងបំផុត និង ជារឿងអំណាចដណ្តើមយកដីពីកូនក្តីខ្ញុំ ។ ហើយជាក់ស្តែងនោះ ឈូ ហុង ពុំមែនជាជនជាតិខ្មែរទេ គាត់ជាសញ្ជាតិបារាំង។

សេចក្តីសន្និដ្ឋានខ្ញុំ សុំឱ្យតុលាការកំពូលបង្វិលរឿងក្តីនេះ ទៅសាលាឧទ្ធរណ៍ វិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ផាត់ ពៅស៊ាង ជាមេធាវីការពារឱ្យដើមចោទបញ្ជាក់ថា : ការដែលថា លោក ឈូ ហុង និង អាន ចំរើន ជាប្តីប្រពន្ធគ្នានោះ ជាការពុំត្រឹមត្រូវទេ ព្រោះ អាន ចំរើន ជាស្រីលួចលាក់របស់កូនក្តីខ្ញុំ តែប៉ុណ្ណោះ ព្រោះ ឈូ ហុង មានប្រពន្ធត្រឹមត្រូវនៅស្រុកបារាំង។ ដូច្នេះ អាន ចំរើន គ្រាន់តែជាអនីតិសង្វាសពុំមានសិទ្ធិចាត់ចែងលើអចលនៈទ្រព្យរបស់កូនក្តីខ្ញុំបានឡើយ ។ ហើយការដែលថា ឈូ ហុង ពុំមែនសញ្ជាតិខ្មែរ ជាការពុំត្រឹមត្រូវឡើយ ព្រោះ ឈូ ហុង ជាខ្មែរសុទ្ធសាធដែលរត់ទៅរស់នៅស្រុកបារាំង ហើយទទួលបានសញ្ជាតិបារាំងតែប៉ុណ្ណោះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់ លោក សៅ វីតា បញ្ជាក់បន្ថែមទៀតថា : បានជាថាឈ្មោះ ឈូ ហុង ពុំមែនជាសញ្ជាតិខ្មែរ គឺដោយមានការបញ្ជាក់ពីរដ្ឋាភិបាលបារាំងថា ឈូ ហុង គឺជាសញ្ជាតិបារាំង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់ លោក ផាត់ ពៅស៊ាង បញ្ជាក់បន្ថែមទៀតថា : ការអះអាងនេះ ពុំត្រឹមត្រូវទេ សុំមើលរូបថតថា លោក ឈូ ហុង ជាបារាំង ឬ ក៏ខ្មែរ ហើយការដែល ឈូ ហុង បានសញ្ជាតិបារាំងនេះ គឺដោយសារគាត់ភៀសខ្លួនពីជាយដែនទៅរស់នៅស្រុកបាំង ។ ដូច្នេះគាត់មានសញ្ជាតិខ្មែរពីកំណើត រួចហើយ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រី អាន ចំរើន និង សារណារបស់លោក ឈូ ហុង និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវី នៃ គូភាគី ។
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤១៦ ចុះថ្ងៃទី ១៨-១០-២០០០ របស់អ្នកស្រី អាន ចំរើន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ ជំនុំជំរះបាន តាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី។

- យល់ឃើញថា ការដែលអ្នកស្រី អាន ចំរើន លើកឡើងក្នុងសារណារបស់អ្នកស្រីថា លោក ឈូ ហុង និង អ្នកស្រី បានរួមរស់ជាមួយគ្នា ជាប្តីប្រពន្ធស្របតាមមាត្រា ៣, ៣០ នៃច្បាប់អាពាហ៍ពិពាហ៍ ហើយលោក ឈូ ហុង ជាជនបរទេស អ្នកស្រីបានកាន់កាប់ផ្ទះនេះអស់ ៨ឆ្នាំ ហើយ

ដែលតាមមាត្រា៤៤ នៃ រដ្ឋធម្មនុញ្ញ និងមាត្រា ៦២ , ៦៥ និង៧៤ នៃច្បាប់ភូមិបាល អ្នកស្រីមានសិទ្ធលើផ្ទះទំនាស់នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះដើមចោទមានប្រពន្ធរួចហើយ ហើយផ្ទះទំនាស់លេខ ១២E០ ផ្លូវ ១៣០ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ៣៦២ ចុះថ្ងៃទី ២៤-៥-៩០ ដោយមានឈ្មោះ ឈូ ហុង ជាម្ចាស់កម្មសិទ្ធិ ហើយ និង មានប័ណ្ណគ្រួសារលេខ ៦០៦ សៀវភៅលេខ ០៤១ ចុះថ្ងៃទី ២៧-៧-៩៩ ដោយមានឈ្មោះ ឈូ ហុង ជាមេគ្រួសារឈ្មោះ តាំង គឹមហៀក ជាប្រពន្ធ ហើយនឹងកូនម្នាក់ផង ។

- យល់ឃើញថា ការដែលមេធាវីរបស់ចុងចម្លើយ លើកឡើងនាពេលសវនាការនេះ ថា លោក ឈូ ហុង ជាជនបរទេសគ្មានសិទ្ធិទិញផ្ទះនៅព្រះរាជាណាចក្រកម្ពុជាទេនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះ ផ្ទះទំនាស់នេះ ជាទ្រព្យសម្បត្តិស្របច្បាប់របស់លោក ឈូ ហុង ហើយក៏ពុំមានអាជ្ញាធរ មានសមត្ថកិច្ចណាទុកជាមោឃៈនូវប័ណ្ណសំគាល់សិទ្ធិលេខ ៣៦២ ចុះថ្ងៃទី ២៤-៥-៩០ ទេ ។ ម្យ៉ាងទៀត ទោះលោក ឈូ ហុង មានសញ្ជាតិបរទេស ក៏អ្នកស្រីពុំអាចឡើងជាកម្មសិទ្ធិករ លើផ្ទះទំនាស់បានទេ ពីព្រោះមិនមែនជាទ្រព្យសម្បត្តិរួម ឬ ជាទ្រព្យសម្បត្តិដោយឡែករបស់អ្នកស្រីទេ ។

- យល់ឃើញថា លោក ឈូ ហុង បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាឧទ្ធរណ៍លេខ ៦២ ចុះថ្ងៃទី ០៧-៨-២០០០ របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ ទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកស្រី អាន ចំរើន កំបាំងមុខលោកឈូ ហុង ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ៤១៦ ចុះថ្ងៃទី ១៨-១០-២០០០ របស់អ្នកស្រី អាន ចំរើន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹង គតិច្បាប់ ។

២- តម្កល់សាលដីកាឧទ្ធរណ៍លេខ ៦២ ចុះថ្ងៃទី ០៧-៨-២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកឈូ ហុង បានបង់ទុកនៅតុលាការកំពូលគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤០០០រៀល ប៉ុន្តែត្រូវដកចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យអ្នកស្រី អាន ចំរើន សងប្រាក់ចំនួន ១៩.០០០រៀលនេះ ទៅលោក ឈូ ហុង វិញ ។

បង្គាប់ឱ្យអ្នកស្រី អាន ចំរើន បង់ពន្ធសមាមាត្រ ១% លើតម្លៃ នៃ ផ្ទះទំនាស់ តាមការជាក់ស្តែង ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០១។